អេស៊ីលីដា ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

## ការធ្វើនិយ័តកម្មភាគហ៊ុនរបស់ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី (ASA, Plc.) នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (CSX)

ធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ’) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់មេត្តាជ្រាបថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី ដែលជាភាគហ៊ុនិកនីតិបុគ្គលមួយរបស់ធនាគារ បានធ្វើនិយ័តកម្មភាគហ៊ុនទាំងអស់ទៅឲ្យភាគហ៊ុនិកជាក់ស្តែងម្នាក់ៗ ដែលមានសមាជិកសរុបចំនួន ១១.៤៨៨នាក់ និងមានភាគហ៊ុនសរុបចំនួន ១០៧.២០៤.៥៤៧ភាគហ៊ុន ស្មើនឹងចំនួន ២៤,៧៤៩២% នៃភាគហ៊ុនសរុបរបស់ធនាគារ ដោយអនុលោមតាមវិធាន ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់និយ័តករមូលបត្រកម្ពុជា និងដោយមានការឯកភាពពីភាគហ៊ុនិកនីមួយៗនៃក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី។ ភាគហ៊ុនដែលបានធ្វើនិយ័តកម្មរួចរាល់នឹងត្រូវដាក់ឲ្យជួញដូរបាននៅលើផ្សារមូលបត្រកម្ពុជាត្រឹម៤% ស្មើនឹង ១៧.៣២៦.៥២១ភាគហ៊ុន សម្រាប់ឆ្នាំ២០២១។ ចំណែកភាគហ៊ុនដែលនៅសល់ចំនួន ២០,៧៤៩២% ទៀតនឹងត្រូវអនុវត្តតាមផែនការជាបន្តបន្ទាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៦កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP